ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ: ០៣៧/សហណ/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ[illegible] ឆ្នាំ២០១៥

**គោរពជូន**

**ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារទីមជ្ឈការ**
**និងវិសហមជ្ឈការនៃក្រសួង ស្ថាប័ន**

**កម្មវត្ថុ** ៖ ការកំណត់ប្រាក់បេសកកម្មសម្រាប់នៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌផអ៣ទី២នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**យោង** ៖ - លិខិតលេខ០០៤ សណន/ គ.ជ.អ.ប ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រាក់បេសកកម្មនៅក្នុងប្រទេសសម្រាប់ក្រសួង ស្ថាប័នក្នុងក្របខ័ណ្ឌផអ៣ទី២នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- ប្រកាសលេខ៨៣០ សហវ.ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ការកំណត់ប្រាក់បេសកកម្មសម្រាប់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌផអ៣ទី២នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវអនុវត្តចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាគ្រប់មុខតំណែងទាំងអស់ ដែលបំពេញការងារនៅ តាមក្រសួង ស្ថាប័ននានា ដោយមានការបម្លាស់ទីចេញពីរង្វង់ដែនដីនៃរាជធានី តាមលក្ខខ័ណ្ឌកំណត់ដូច ខាងក្រោម ៖

**១. បេសកកម្មក្នុងប្រទេស**

- បម្លាស់ទីក្នុងរង្វង់ដែនដីនៃរាជធានី (ពីក្រសួង ស្ថាប័នមួយទៅក្រសួង ស្ថាប័នដទៃ ឬពីក្រសួង ស្ថាប័នទៅខណ្ឌ សង្កាត់នានាក្នុងរង្វង់ដែនដីរាជធានី) នឹងមិនទទួលបានរបបបេសកកម្មឡើយ ទោះបីចម្ងាយផ្លូវប៉ុន្មានក៏ដោយ។
- បម្លាស់ទីរបស់ក្រសួង ស្ថាប័ន (ចេញពីរង្វង់ដែនដីនៃរាជធានីដែលមានទីតាំងរបស់ក្រសួង ស្ថាប័ននានាតាំងនៅ ទៅកាន់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់) នឹងទទួលបានរបបបេសកកម្ម ៖
  - ផ្តល់ជូនប្រាក់ឧបត្ថម្ភចំនួន០៥(ប្រាំ)ដុល្លារ ក្នុងករណីដែលមានការបម្លាស់ទីចេញពីរង្វង់ដែនដីរាជធានីចម្ងាយតិចជាង២០(ម្ភៃ)គីឡូម៉ែត្រ។
  - ផ្តល់ជូនប្រាក់ហោប៉ៅ និងប្រាក់ហូបចុកដែលមានចំនួន១៤(ដប់បួន)ដុល្លារ ក្នុងករណីដែលមានការបម្លាស់ទីចម្ងាយចេញពីរង្វង់ដែនដីរាជធានីលើសពី២០(ម្ភៃ) គីឡូម៉ែត្រឡើងទៅ។
  - ផ្តល់ជូនបន្ថែមនូវប្រាក់ស្នាក់នៅចំនួន២០(ម្ភៃ)ដុល្លារ ក្នុងករណីដែលការបម្លាស់ទីចេញ



មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ : (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS), Ministry of Interior. Tel: (855-23) 720 061 / 720 038

ពីរង្វង់ដែនដីរាជធានីចម្ងាយលើសពី៤០(សែសិប) គីឡូម៉ែត្រ និងជាបេសកកម្មដែលតម្រូវឱ្យមានការស្នាក់នៅពេលយប់ តាមការសម្រេចរបស់ថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ន។ ថ្ងៃត្រឡប់មកពីបំពេញបេសកកម្មស្នាក់នៅពេលយប់វិញនឹងផ្តល់ជូនប្រាក់ហោប៉ៅ និងប្រាក់ហូបចុកដែលមានទឹកប្រាក់សរុបចំនួន១៤(ដប់បួន)ដុល្លារ។

- រាល់ការបំពេញបេសកកម្មក្នុងប្រទេស សោហ៊ុយធ្វើដំណើរតាមយន្តហោះមិនត្រូវផ្តល់ជូនទេ។
- គោលការណ៍នានាសម្រាប់ធានាការអនុវត្តបេសកកម្មប្រកបដោយប្រសិទ្ធភាព និងការសន្សំសំចៃដូចមានចែងក្នុងលិខិតលេខ០០៤ សណន/ គ.ជ.អ.ប ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រាក់បេសកកម្មនៅក្នុងប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌ ផអ៣ទី២នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅមានសុពលភាពអនុវត្តជាបន្ត។

**២. បេសកកម្មក្រៅប្រទេស**

- ការបំពេញបេសកកម្មក្រៅប្រទេសរបស់ក្រសួង ស្ថាប័ន នៅតាមតំបន់ជាប់ព្រំដែនជាមួយព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងប្រការ២១នៃប្រកាសលេខ៨៣០ សហវ.ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ នឹងទទួលបានប្រាក់បេសកកម្មស្មើគ្នានឹងចំនួនប្រាក់បេសកកម្មក្នុងប្រទេស ដូចមានកំណត់ក្នុងផ្នែកទី១ខាងលើ។
- ផ្តល់ជូនប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងប្រាក់ស្នាក់នៅសម្រាប់បេសកកម្មនៅក្រៅប្រទេសក្នុងអត្រារួមមួយដែលមានចំនួនសរុបស្មើនឹង មុខតំណែងប្រភេទ ង ដូចមានកំណត់ក្នុងមាត្រា១៣ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកកិច្ចសន្យារបស់ក្រសួង ស្ថាប័នគ្រប់មុខតំណែងទាំងអស់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមស្នើឯកឧត្តម លោកជំទាវ មេត្តាចាត់ចែង និងអនុវត្តតាមស្មារតីនៃលិខិតនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកជំទាវមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន**
**លេខាធិការដ្ឋាន គ.ជ.អ.ប**

សក់ សេដ្ឋា

ចម្លងជូន ៖
- ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា
- គម្រោង កម្មវិធីនានា
  "ដើម្បីជ្រាប"
- ឯកសារ-កាលប្បវត្តិ